ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង៖ ១២២/១១-ឌី វ៉ាលបេស

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក៖ ឈើរ ភិរម្យ

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត៖ ទូន ស៊ីផាន់

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា)

អាសយដ្ឋាន ៖ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៤៥ ០៥៣ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

-សវនាការលើកទី១៖

១- លោកស្រី សិទ្ធ សុគន្ធារុណ ប្រធានរដ្ឋបាល

២- លោក ឡា សិទ្ធិកា រដ្ឋបាល

-សវនាការលើកទី២៖

- លោកស្រី សិទ្ធ សុគន្ធារុណ ប្រធានរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហព័ន្ធសហជីពសាមគ្គីភាព

- សហជីពសាមគ្គីភាព រោងចក្រ ឌី វ៉ាលបេស

អាសយដ្ឋាន ៖ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ ៖ ០១២ ៣៣០ ១៨១ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតៈ

-សវនាការលើកទី១៖

| | |
|---|---|
| ១- លោក ណៃ សុខវ៉ាសនា | ប្រធានសហព័ន្ធសហជីពសាមគ្គីភាព |
| ២- លោក សន ប្រាក់ | អគ្គលេខាធិការសហព័ន្ធសហជីពសាមគ្គីភាព |
| ៣- លោកស្រី គង់ ស្រីណា | ប្រធានសហជីពសាមគ្គីភាព ក្រុមហ៊ុន ឌី វ៉ាលបេស |
| ៤- លោកស្រី អៀង សារ៉ុន | អនុប្រធានសហជីពសាមគ្គីភាព ក្រុមហ៊ុន ឌី វ៉ាលបេស |
| ៥- លោកស្រី ទូច វណ្ណៈ | លេខាធិការសហជីពសាមគ្គីភាព ក្រុមហ៊ុន ឌី វ៉ាលបេស |
| ៦- លោក នី វណ្ណៈ | សកម្មជនសហជីព |
| ៧- លោក ឈុំ សុខុម | សកម្មជនសហជីព |
| ៨- លោកស្រី សៀន ផាន | ហិរញ្ញិកសហជីព |
| ៩- លោកស្រី ប៉ុល សារី | សមាជិកសហជីព |

-សវនាការលើកទី២ ៖ **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនដកប្រធានផ្នែក ក្រុមទី០៥ ឈ្មោះ សុខ ភា ចេញពីក្រុមហ៊ុន។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា មិនអាចដកប្រធានផ្នែក ក្រុមទី០៥ ឈ្មោះ សុខ ភា បានទេ។

២- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកអ្នកស្រី ប៉ុល សារី ចូលធ្វើការវិញ ព្រោះនៅពេលដែលគាត់មានគ្រោះថ្នាក់ការងារ ក្រុមហ៊ុនបានបង្ខំឱ្យគាត់លាឈប់ពីការងារ ព្រមទាំងសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួលប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនគាត់ រហូតដល់ថ្ងៃជាសះស្បើយ ហើយចូលធ្វើការវិញ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ពុំបានបង្ខំឱ្យអ្នកស្រី ប៉ុល សារី លាឈប់ពីការងារឡើយ គឺគាត់បានលាឈប់ពីការងារដោយខ្លួនឯង។

៣- សុំមិនឱ្យក្រុមហ៊ុនធ្វើការផ្លាស់ប្តូរកន្លែងការងាររបស់ថ្នាក់ដឹកនាំសហជីពឡើយ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះការផ្លាស់ប្តូរកន្លែងធ្វើការងាររបស់កម្មករនយោជិត គឺជាសិទ្ធិចាត់តាំងរបស់ក្រុមហ៊ុន។

៤- ទាមទារមិនឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់លើកទឹកចិត្តថ្នាក់ដឹកនាំសហជីព ឬអ្នកដែលចូលជាសមាជិកសហជីព ដោយគ្មានហេតុផលឡើយ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ការផ្តល់រង្វាន់លើកទឹកចិត្ត គឺក្រុមហ៊ុនផ្តល់ចំពោះកម្មករនិយោជិត ដែលធ្វើការយកចិត្តទុកដាក់ក្នុងការងារ។

៥- កម្មករនិយោជិតសុំនៅពេលឈប់មួយថ្ងៃ មិនត្រូវកាត់ប្រាក់រង្វាន់បីថ្ងៃឡើយ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា អនុវត្តទៅតាមគោលការណ៍ចាស់របស់ក្រុមហ៊ុន។

-កម្មករនិយោជិតសុំទៅពេលឈប់មួយថ្ងៃក្នុងមួយខែ មិនត្រូវកាត់ប្រាក់ប៉ុវឡើយ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា អនុវត្តទៅតាមគោលការណ៍ចាស់របស់ក្រុមហ៊ុនដែរ ។

៦- ផ្ទាក់ដឹកនាំសហជីពសាមគ្គីភាពទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ឈុំ សុខខុំ ចូលធ្វើការវិញ ព្រោះក្រុមហ៊ុនរើសអើងសហជីព។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា មិនអាចទទួលយកលោក ឈុំ សុខខុំ ឱ្យចូលធ្វើការវិញឡើយ ព្រោះលោកបានដល់កិច្ចសន្យាការងារ ក្រុមហ៊ុនមិនធ្វើការជួលបន្ត ហើយក្រុមហ៊ុនទូទាត់ប្រាក់បំណាច់ផ្សេងៗទៅតាមច្បាប់ស្តីពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១០៦៨ កប/អក/វក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖

-លើកទី១ ៖ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ (វេលាម៉ោង ១៤៖០០ នាទី រសៀល ) ។

-លើកទី២ ៖ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ (វេលាម៉ោង ១៤៖០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹង របស់សហព័ន្ធសហជីពសាមគ្គីភាព លេខ ០៦០/១១ សសស ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការទាមទារសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ១១ ចំណុច។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងារនេះ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៦ ចំណុច លើការទាមទារចំនួន ១១ ចំណុច។ ចំណុចមិនសះជាចំនួន ០៦ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋាន

ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ឌី វ៉ាលបេស លេខ ១០៦៨ កប/អក/វក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១០ ចំណុចនេះ លើកទី១ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ១៤៖០០ នាទី រសៀល និលើកទី២ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ១៤៖០០ នាទី រសៀល ។ នៅថ្ងៃសវនាការលើកទី១ ភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតបានអញ្ជើញមកចូលរួមសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប៉ុន្តែ នៅថ្ងៃសវនាការលើកទី២នេះ ភាគីក្រុមហ៊ុនបានអញ្ជើញចូលរួមសវនាការតាមការអញ្ជើញ។ ដោយឡែក ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមិនបានបញ្ជាក់ពីមូលហេតុ សម្រាប់ការមិនចូលរួមនេះទេ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការផ្ទេរសិទ្ធិជូនឈ្មោះ សិទ្ធ សុគន្ធារុណ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១។

២- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកប្រធានសហជីពឯករាជ្យកម្មករ នៃក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២ លេខ ៥៤៣ កប/អក/វក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០។

៣- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពឯករាជ្យ នៃក្រុមហ៊ុន ឌីវ៉ាលបេស (ខេមបូឌា) ចុះបញ្ជិកាលេខ ១២៤៣ កប/វក. ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧។

៤- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត របស់សហជីពសហជីពឯករាជ្យ នៃក្រុមហ៊ុន ឌីវ៉ាលបេស (ខេមបូឌា) លេខ ០០៥/០៨ ក.ប/វ.ប ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៨។

៥- លិខិតរបស់ប្រធានសហជីពឯករាជ្យកម្មករ នៃក្រុមហ៊ុន ឌីវ៉ាលបេស (ខេមបូឌា) គោរពជូន លោកនាយកក្រុមហ៊ុន ឌីវ៉ាលបេស (ខេមបូឌា) ស្តីពីការផ្លាស់ប្តូរបេក្ខភាពឈរឈ្មោះជាតំណាងកម្មករ ឈ្មោះ ឈុំ សុខខុំ ជំនួសដោយ អ្នកស្រី នួន ម៉ាលី វិញ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១។

៦- ពាក្យសុំចូលបំរើការងារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ កិច្ចសន្យាការងារកំណត់ថិរវេលាជាក់លាក់ របស់ឈ្មោះ ឈុំ សុខខុំ។

៧- តារាងសង្ខេបប្រាក់ខែសម្រាប់ខែសីហា ឆ្នាំ២០១១។

៨- លិខិតរបស់ប្រធានសហជីពឯករាជ្យកម្មករ នៃក្រុមហ៊ុន ឌីវ៉ាលបេស (ខេមបូឌា) គោរពជូន លោកនាយក ក្រុមហ៊ុន ឌីវ៉ាលបេស (ខេមបូឌា) ស្តីពីការបញ្ជូនឈ្មោះបេក្ខភាពឈរឈ្មោះជាតំណាងកម្មករ ចំនួន ៣២ រូប សំរាប់អាណត្តិទី៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១។

៩- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកនាយកក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក អាណត្តិទី៣ លេខ ៩៨០ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០។

១០- កំណត់ហេតុស្តីពីការបោះឆ្នោតជ្រើសរើសបុគ្គលិកប្រចាំក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) សំរាប់ អាណត្តិទី៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។

១១- សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក (សម្រាប់អាណត្តិទី៣) ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០១១។

១២- អនុសញ្ញារួម រវាងសហជីពឯករាជ្យកម្មករ និងអ្នកគ្រប់គ្រងក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ចុះបញ្ជិកាលេខ ០៧៦ កប/អក/វក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨។

១៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ចុះបញ្ជិកាលេខ ១៣៩ កប/អក/វក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០៧។

១៤- លក្ខន្តិកៈរបស់ក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ចុះបញ្ជីពាណិជ្ជកម្ម លេខ ១៥៥/០៧ ពណ.នតក.បព ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៧។

១៥- វិញ្ញាបនប័ត្របញ្ជាក់ក្នុងឈ្មោះបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) លេខ ០២២៧ ពណ.នតក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៧។

១៦- លិខិតរបស់ឈ្មោះ មឿន ស្រីមុំ ធ្វើការនៅផ្នែកវេចខ្ចប់ សូមស្រាយបំភ្លឺថា ចំពោះករណីលាឈប់ពី ការងាររបស់ម្តាយនាងខ្ញុំ ឈ្មោះ ប៉ុល សារី អត្តលេខ ៨៣១០ ដោយគ្មានការគំរាមកំហែងពីក្រុមហ៊ុន ឡើយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១។

១៧- លិខិតរបស់ឈ្មោះ ប៉ុល សារី ស្តីពីការសុំលាឈប់ពីការងារ។

១៨- ពាក្យបញ្ឈប់ពីការងារ របស់ឈ្មោះ ឈុំ សុខខុម។

១៩- លិខិតជូនដំណឹង របស់ក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) សូមជំរាបជូនលោក ឈុំ សុខុម ស្តីពីកិច្ច សន្យាការងាររបស់លោកនឹងត្រូវបញ្ចប់នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ ហើយក្រុមហ៊ុនមិនបន្តកិច្ច សន្យាកាងារជូន ចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ នេះតទៅ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ។

២០- កាតសំគាល់ម៉ោងចេញ ចូលធ្វើការងាររបស់ ឈ្មោះ ឈុំ សុខខុំ ខែសីហា ឆ្នាំ២០១១ ។

២១- កិច្ចសន្យាការងារកំណត់ថិរវេលាជាក់លាក់ របស់ឈ្មោះ ឈុំ សុខខុំ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ ។

២២- តារាងប្រាក់ឈ្នួល ប្រចាំខែកញ្ញា ឆ្នាំ២០១១ ។

២៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឌី វ៉ាលបេស ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ។

២៤- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកនាយកក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក អាណត្តិទី២ លេខ ៧៤៨ ក.ប/អក/វក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩។

២៥- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ឌី វ៉ាលបេស ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងកម្មករនិយោជិត សំរាប់អាណត្តិទី០៣ ដែលប្រព្រឹត្តនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ។

២៦- ពាក្យសុំលាឈប់ពីការងាររបស់ឈ្មោះ គង់ ស្រីណា ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ ។

២៧- ពាក្យសុំលាឈប់ពីការងាររបស់ឈ្មោះ អៀង សារ៉ុន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ។

២៨- លិខិតរបស់ឈ្មោះ នី វណ្ណៈ ស្តីពីសុំដកខ្លួនចេញពីសហជីពសាមគ្គីភាព ចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ។

២៩- សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក (សម្រាប់អាណត្តិទី៣) ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- បង្កាន់ដៃទទួលសំណុំរឿង របស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការចុះបញ្ជិកាសហជីពសាមគ្គីភាព នៃក្រុមហ៊ុន ឌី វ៉ាលបេស ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ។

២- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ឌី វ៉ាលបេស ស្តីពីការជ្រើសរើស បេក្ខជនឈរឈ្មោះបោះឆ្នោតតំណាងកម្មករនិយោជិត សំរាប់អាណត្តិទី៣ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ។

៣- ប័ណ្ណអនុញ្ញាតឱ្យឈ្មោះ ប៉ុល សារី ចេញពីមន្ទីរពេទ្យព្រះកុសមៈ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១១ ។

៤- សាលាកប័ត្រផ្ញើសេវា EMS ក្នុងប្រទេស ពីសហព័ន្ធសហជីពសាមគ្គីភាព ផ្ញើទៅលោកអគ្គនាយកក្រុមហ៊ុន ឌី វ៉ាលបេស ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ។

៥- លិខិតលេខ ០៦១/១១ សសស ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ របស់គណៈកម្មាធិការសហព័ន្ធសហជីពសាមគ្គីភាព គោរពជូន លោកអគ្គនាយកក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ស្តីពីជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីពសាមគ្គីភាព នៃក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) អាណត្តិទី១ ។

៦- លិខិតលេខ ០៥៥/១១ សសស ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ របស់គណៈកម្មាធិការសហព័ន្ធសហជីពសាមគ្គីភាព គោរពជូន លោកអគ្គនាយកក្រុមហ៊ុន ឌី វ៉ាលបេស (ខេមបូឌា) ស្តីពីជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីពសាមគ្គីភាព នៃរោងចក្រកាត់ដេរ ឌី វ៉ាលបេស អាណត្តិទី១ ។

៧- បង្កាន់ដៃទទួលសំណុំរឿង របស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការចុះបញ្ជិកាសហជីពសាមគ្គីភាព នៃក្រុមហ៊ុន ឌី វ៉ាលបេស ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឌី វាលបេស លេខ ១០៦៨ កប/អក/វក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឌី វាលបេស ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៦៩៤ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៧៤៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៧៥០ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ។

៥- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០១១ ។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនៅក្នុងសំណុំរឿងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិតអវត្តមាននៅថ្ងៃសវនាការលើកទី២ ដោយគ្មានបញ្ជាក់មូលហេតុ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតមិនបានចូលរួមគ្រប់ដំណាក់កាល នៅក្នុងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមការអញ្ជើញទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោមៈ

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេល ដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន។ "*

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី និងលេខ ២៧/០៧-អ៊ីម និង វ៉េ ៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបិទសំណុំរឿងបាន *" លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន "* ។

ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**<u>លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានទទួលការអញ្ជើញត្រឹមត្រូវ</u>**

មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានញ្ជើញភាគីកម្មករនិយោជិតមកចូលរួមសវនាការអាជ្ញាកណ្តាលត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញឱ្យចូលរួមសវនាការលើកទី១ លេខ ៦៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ និងលិខិតអញ្ជើញឱ្យចូលរួមសវនាការលើកទី២ លេខ ៧៥០ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យមកចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទាំងពីរលើកពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី ១ ត្រូវបានបំពេញ។

**<u>លក្ខខណ្ឌទី ២ ៖ ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល</u>**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យ "បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល" នៅក្នុងប្រការ ២១ នៃប្រកាស លេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល តាំងពីដើមរហូតដល់ចប់សព្វគ្រប់។

ដំណើរការសវនាការអាជ្ញាកណ្តាល ដែលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់ការណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់ការពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់ការផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ នៅថ្ងៃសវនាការលើកទី១ ភាគីនិយោជក និងភាគីកម្មករនិយោជិតបាន អញ្ជើញមកចូលរួមសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសួររកនូវអង្គហេតុ និងហេតុផលនៃការទាមទារដែលពាក់ព័ន្ធនឹងចំណុចវិវាទនីមួយៗ។ ពេលនោះ ភាគីកម្មករនិយោជិតបានលើកឡើងថា ពួកគាត់មិនបានយកមកជាមួយនូវឯកសារ និង ភស្តុតាងមួយចំនួនដូចជា កំណត់ហេតុបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព និងលិខិតជូនដំណឹងស្តីពីលទ្ធផល នៃការបោះឆ្នោត ។ល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សវនាការលើកទី១ គឺភាគីកម្មករនិយោជិតមិនបានបង្ហាញ នូវអង្គហេតុសំខាន់ៗ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចពិចារណានោះទេ។

ដោយមូលហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជកមកសវនាការជាលើកទី២ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ១៤:០០ នាទី រសៀល។ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានចូលរួមសវនការលើកទី២ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ គឺមានតែភាគីនិយោជកដែលបានអញ្ជើញចូលរួមសវនាការតាមការអញ្ជើញ។ ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ថ្នាក់ដឹកនាំសហជីពលោកស្រី គង់ ស៊ីណា ដែលជាប់ឆ្នោតជាប្រធានសហជីព បានលាឈប់ពីការងារ ដូចមានលិខិតសុំលាឈប់ពីការងាររបស់សាម៉ីខ្លួន ចុះថ្ងៃទី១២ ខែតុលា ឆ្នា២០១១ និងលោកស្រី អៀង សារ៉ុន ដែលជាប់ជាអនុប្រធានសហជីពបានលាឈប់ពីការងារ ដូចមានលិខិតសុំលាឈប់ពីការងាររបស់សាម៉ីខ្លួន ចុះថ្ងៃទី១៥ ខែតុលា ឆ្នា២០១១ ។ ចំណែកឯលោកស្រី ប៉ុល សារី ដែលក្រុមហ៊ុនបានព្រមព្រៀងទទួលយកចូលធ្វើការវិញ ដូចមាននៅក្នុងកិច្ចព្រមព្រៀងចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ ក៏សាម៉ីខ្លួនមិនបានចូលមកធ្វើការវិញដែរ រហូតមកដល់ពេលនេះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងសវនការលើកទី២នេះ គឺជាសវនាការដើម្បីប្រមូលអង្គហេតុ និងភស្តុតាងសំខាន់ៗ ហើយភាគីកម្មករនិយោជិតមានបន្ទុកផ្តល់នូវអំណះអំណាង ឯកសារ និងភស្តុតាង ដើម្បីគាំទ្រដល់ការទាមទាររបស់ខ្លួន។ ប៉ុន្តែ ភាគីកម្មករនិយោជិតបែជាអវត្តមាន ដោយគ្មានបញ្ជាក់ពីមូលហេតុទៅវិញ។

ដូចនេះ ភាគីកម្មករនិយោជិត មិនបានចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់ នៃនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមិនបានបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលតាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ ២១ ខាងលើនេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។**

## <u>លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន</u>

ក្នុងករណីនេះ ភាគីកម្មករនិយោជិត មិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនចូលរួមសវនាការលើកទី២ទេ ដោយភាគីកម្មករនិយោជិតបានបញ្ជាក់ថា ខ្លួនមិនមកចូលរួមសវនាការបានទេ ហើយសុំឱ្យអាជ្ញាកណ្តាលចេញសេចក្តីបង្គាប់តាមនីតិវិធី។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួននេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី ៣ ក៏ត្រូវបានបំពេញដែរ។**

ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងក្នុងការធ្វើការការពារ ចំពោះការទាមទាររបស់កម្មករនិយោជិតដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានជ្រើសរើសការមិនចូលរួមនៅក្នុងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យចប់សព្វគ្រប់នោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមានចេតនាមិនចូលរួមដោះស្រាយវិវាទរបស់ខ្លួនជាមួយនិយោជកតាមនីតិវិធីដែលច្បាប់តម្រូវនោះឡើយ។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណីភាគីដើមបណ្តឹងមិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈដោយសុទ្ធចិត្តរបស់ភាគីកម្មករនិយោជិតក្នុងការយកវិវាទការងាររបស់ខ្លួនមកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ១២២/១១-ឌី វ៉ាលបេស នេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

*- បិទសំណុំរឿងលេខ ១២២/១១-ឌី វ៉ាលបេស។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក:

ឈ្មោះ៖ **ឈឹម គិរម្យ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត:

ឈ្មោះ៖ **ទួន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល:

ឈ្មោះ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------